# សេចក្តីប្រកាសព័ត៌មាន

## ប្រធានសិទ្ធិមនុស្ស អ.ស.ប. ថ្លែងថា "យូរ ឬឆាប់ អ្នកធ្វើទារុណកម្មនឹងត្រូវផ្តន្ទាទោស"

*សេចក្តីថ្លែងការណ៍របស់ លោកស្រី ណាវី ភីឡៃ*
*ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស សម្រាប់ថ្ងៃទី២៦ ខែមិថុនា*
*ដែលជាទិវាអន្តរជាតិដើម្បីគាំទ្រជនរងគ្រោះដោយសារអំពើទារុណកម្ម*

ចាប់ផ្តើមនៅក្នុងឆ្នាំ១៩៧៦ អំឡុងពេលនៃរបបយោធាផ្តាច់ការនៅអាហ្សង់ទីន លោក អាបេល ឌូពុយ ប្រធានពន្ធនាគារ បានបញ្ជាឲ្យធ្វើទារុណកម្ម និងប្រព្រឹត្តកម្មយ៉ាងឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាបជាប្រព័ន្ធ លើអ្នកទោសនយោបាយជាច្រើន ដែលអាចមានចំនួនរហូតដល់រាប់រយនាក់។

ជនជាប់ឃុំមកដល់ថ្មីបានត្រូវស្វាគមន៍ដោយឆ្មាំពន្ធនាគារ ដែលឈរជាពីរជួររង់ចាំវាយដំពួកគេ ខណៈដែលពួកគេដើរចូលក្នុងពន្ធនាគារទាំងជាប់ខ្នោះដៃ និងគ្របមុខជិត។ ជានិច្ចកាលពួកគេត្រូវសម្រាតសម្លៀកបំពាក់ចេញ មុនពេលចាប់ផ្តើមធ្វើទារុណកម្ម។

ជនរងគ្រោះទាំងឡាយ បានទទួលរងការឈឺចាប់យ៉ាងធ្ងន់ធ្ងរផ្នែកផ្លូវកាយ និងផ្លូវចិត្ត ខណៈដែលអ្នកបញ្ជាឲ្យធ្វើទារុណកម្ម បានបន្តរស់នៅក្នុងទីក្រុង ប៊ូណុស អ៊ែរ៉េស យ៉ាងមានសេរីភាព រហូតដល់ច្រើនទសវត្សរ៍ក្រោយមក ទើបមានដីកាចាប់ខ្លួន ត្រូវបានចេញដើម្បីចាប់ខ្លួន លោក ឌូពួយ។ កាលពីខែតុលាឆ្នាំមុននេះ គឺអស់រយៈពេល៣០ឆ្នាំបន្ទាប់ពីការថ្កោលទោសដំបូងប្រឆាំងនឹងអំពើឃោរឃៅរបស់គាត់ ទីបញ្ចប់យុត្តិធម៌ត្រូវបានរកឃើញ នៅពេលដែល លោក ឌូពួយ ត្រូវបានផ្តន្ទាទោស និងដាក់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត។

នៅតំបន់ភាគច្រើននៃអាមេរិកឡាទីន និងតំបន់ដទៃផ្សេងៗទៀតនៅទូទាំងពិភពលោក យើងបានមើលឃើញការរីកចំរើនគួរឲ្យអបអរសាទរ ក្នុងការអនុវត្តន៍ការហាមឃាត់យ៉ាងតឹងរ៉ឹងប្រឆាំងនឹងការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មផ្សេងៗបែបឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប នៅក្នុងច្បាប់អន្តរជាតិ ជានិច្ចកាលជាច្រើនឆ្នាំបន្ទាប់ពីបទឧក្រិដ្ឋបែបនោះ ត្រូវបានប្រព្រឹត្តឡើង។

មកត្រឹមខែតុលាឆ្នាំមុននេះ នៅប្រទេសអាហ្សង់ទីន មានមនុស្សចំនួន៧៤៨នាក់ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដែលបានប្រព្រឹត្តនៅអំឡុងពេលនៃសករាជរបបយោធា ហើយមានមនុស្សចំនួន៨១នាក់ រាប់បញ្ចូលទាំងលោក ឌូពួយ ផង ត្រូវបានផ្តន្ទាទោស។ នៅប្រទេសកូឡុំប៊ី ច្បាប់ស្តីពីជនរងគ្រោះថ្មីមួយ បានចែងអំពីបទប្បញ្ញត្តិនានា ដែលកំណត់ពីការសំណងការខូចខាត បដិទាន និងវិធានការផ្សេងៗទៀតសម្រាប់ជនរងគ្រោះនៃអំពើរំលោភសិទ្ធិមនុស្សនានា ដែលបានប្រព្រឹត្តនៅកំឡុងពេលមានជម្លោះ។ ការចាប់ខ្លួនលោក រ៉ាដូវ៉ាន់ ការ៉ាដហ្សិក និងលោក រ៉ែតកូ ម្ល៉ាឌិច និងការចោទប្រកាន់ពួកគេពីបទរំលោភ

សិទ្ធិមនុស្ស និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រាប់បញ្ចូលទាំងអំពើធ្វើទារុណកម្ម ក៏បានពង្រឹងផងដែរ ដល់ការតស៊ូនៅទូទាំងសកលលោកប្រឆាំងនឹងនិទណ្ឌភាព។ សរុបទាំងអស់ សាលាជំនុំជម្រះឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី បានចោទប្រកាន់មនុស្សចំនួន ១៦១នាក់ ហើយភាគច្រើននៃករណីទាំងនេះ អំពើធ្វើទារុណកម្មត្រូវបានរួមបញ្ចូលជាបទចោទប្រកាន់ផងដែរ។

ការធ្វើទារុណកម្មគឺជាអំពើខុសច្បាប់ ហើយប្រសិនបើអំពើបែបនេះប្រព្រឹត្តទៅដោយមានលក្ខណៈជាប្រព័ន្ធនោះ វាអាចត្រូវចាត់ទុកថាជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ ទោះបីជាក្នុងករណីពិសេសក៏ដោយ ពុំមានកាលៈទេសៈណាមួយ ផ្តល់យុត្តិកម្មដល់ការប្រើប្រាស់ទារុណកម្មប្រឆាំងនឹងនរណាម្នាក់ សម្រាប់ហេតុផលណាមួយឡើយ។ ពុំមានស្ថានការណ៍គ្រាអាសន្ន ឬជម្លោះណាមួយ  ពុំមានការប្រយុទ្ធប្រឆាំងនឹងអំពើភេរវកម្ម ឬការប្រយុទ្ធប្រឆាំងនឹងបទឧក្រិដ្ឋណាមួយ លើកលែងដល់ការធ្វើទារុណកម្មនោះឡើយ។ ការអនុវត្តន៍ទាំងនេះ ធ្វើឲ្យបាត់បង់ភាពជាមនុស្សទាំងរបស់ជនរងគ្រោះ និងជនល្មើស ហើយបន្សល់ទុកនូវស្លាកស្នាម លើបុគ្គល សហគមន៍ និងសង្គមទាំងមូល ដែលអាចពិបាកនឹងជាសះស្បើយ ។ ដំណើរការនៃការជាសះស្បើយ ត្រូវចាប់ផ្តើមជាមួយនឹងយុត្តិធម៌ ហើយត្រូវផ្សាភ្ជាប់នឹងដំណើរការនៃការស្តារនីតិសម្បទារយៈពេលដ៏វែងមួយសម្រាប់ជនរងគ្រោះ និងជនល្មើស ក៏ដូចជាការជួសជុលការខូចខាតផងដែរ។ វិធានការទាំងនេះ ត្រូវការផ្សាភ្ជាប់នឹងការបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់នានា និងការមិនអត់ឱនចំពោះការប្រើប្រាស់អំពើទារុណកម្ម។

គួរឲ្យសោកស្តាយ ទោះបីជាមានច្បាប់អន្តរជាតិហាមឃាត់ការធ្វើទារុណកម្ម និងប្រព្រឹត្តកម្មបែបឃោរឃៅអមនុស្សធម៌ ឬបន្ថោកបន្ទាបក៏ដោយ ក៏ការអនុវត្តន៍ដ៏យង់ឃ្នងបែបនេះនៅតែត្រូវបានចងក្រងជារៀងរាល់ថ្ងៃ។ ការប្រើប្រាស់ទារុណកម្ម ដែលជាសញ្ញាណរួមនៃការរំលោភអំណាចរបស់រដ្ឋាភិបាល និងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌដែលមិនដំណើរការ គឺមានលក្ខណៈទូទៅពេក។ ដូចយើងបានឃើញយ៉ាងជាក់ស្តែងនៅក្នុងប្រទេសអាហ្វ្រិកខាងជើង និងមជ្ឈឹមបូព៌ាកាលពីប៉ុន្មានខែកន្លងទៅ បុរស ស្ត្រី និងកុមារជាច្រើនត្រូវបានគេធ្វើទារុណកម្មនៅក្នុងកន្លែងឃុំឃាំងដើម្បីបង្ខំយកចម្លើយសារភាព គ្រាន់តែដោយសារការបញ្ចេញទស្សនៈនយោបាយរបស់ខ្លួន ឬដោយសារតែពួកគេស្ថិតនៅទីកន្លែងមួយមិនត្រឹមត្រូវ ក្នុងពេលវេលាមិនសមស្រប។

នៅពីក្រោយការប្រើប្រាស់ជាទូទៅ គឺការរំពឹងទុកថានឹងទទួលបាននិទណ្ឌភាពចំពោះអ្នកដែលបញ្ជាអ្នកដែលអនុវត្តអំពើទារុណកម្ម និងអ្នកដែលបិទភ្នែកធ្វើមិនដឹងមិនឮដោយចេតនាចំពោះអំពើធ្វើទារុណកម្ម។
.
ដោយសារតែភាពក្លាហាន និងការប្តេជ្ញាចិត្តរបស់ជនរងគ្រោះ និងអ្នកនៅមានជីវិត ព្រមទាំងកិច្ចខិតខំប្រឹងប្រែងដោយមិននឿយហត់របស់អ្នកការពារសិទ្ធិមនុស្សនានា ធ្វើឲ្យគណនីយភាពនៃការធ្វើទារុណកម្មកាន់តែកើនឡើង ហើយជនល្មើសដែលប្រព្រឹត្តអំពើទារុណកម្ម គួរឈប់រំពឹងថា នឹងរួចផុតពីការទទួលខុសត្រូវនៃអំពើដ៏យង់ឃ្នងរបស់ខ្លួនតទៅទៀត។

ក្រោយពីមានការប្រព្រឹត្តបទឧក្រិដ្ឋកម្មធ្វើទារុណកម្មអស់ជាច្រើនទសវត្សរ៍មក  ការផ្តន្ទាទោសនៃបទល្មើសបែបនេះ ដែលយើងកំពុងមើលឃើញបច្ចុប្បន្ននេះ គឺជាការបញ្ជូនសារដ៏មុឺងម៉ាត់មួយ។ ករណីទាំងឡាយដូចជាករណីលោក ឌូពុយ បង្ហាញយ៉ាងច្បាស់ថា នៅពេលដែលពេលវេលាផ្លាស់ប្តូរ របបក៏ផ្លាស់ប្តូរដែរ ដូចដែលអ្វីៗបានកើតមានឡើងនៅអាមេរិកឡាទីនកាលពីចុងសតវត្សរ៍ទី២០ ហើយដូចអ្វីៗ ដែលបច្ចុប្បន្នកំពុងកើតមានឡើងនៅអាហ្វ្រិកខាងជើង និងមជ្ឈឹមបូព៌ាដែរ។ ពិតណាស់ ជនរងគ្រោះមួយក្នុងចំណោម

ជនរងគ្រោះដោយអំពើរបស់លោក ឌូពុយ គឺលោក ជូស តាយ៉ាណា បានក្លាយជារដ្ឋមន្ត្រីការបរទេស របស់ប្រទេសអាហ្សង់ទីន ហើយបានផ្តល់សក្ខីកម្មនៅសាវនាការរបស់លោក ឌូពុយកាលពីឆ្នាំមុន។

ការពង្រឹងយន្តការយុត្តិធម៌អន្តរជាតិ រួមបញ្ចូលទាំងតុលាការឧក្រិដ្ឋកម្មអន្តរជាតិដែលកាន់តែមានភាពចាស់ទុំ យ៉ាងឆាប់រហ័សនោះ មានន័យថា ឱកាសដែលអ្នកធ្វើទារុណកម្មនឹងត្រូវជាប់អន្ទាក់នៅថ្ងៃណាមួយ ទោះជានៅថ្នាក់ជាតិ ឬអន្តរជាតិក្តី កាន់តែមានកម្រិតខ្ពស់ឡើង។

រដ្ឋាភិបាល និងមន្ត្រីដែលរំលោភអំណាចនានា ត្រូវយកចិត្តទុកដាក់ថា៖ អំពើទារុណកម្ម គឺជាបទឧក្រិដ្ឋ អន្តរជាតិធ្ងន់ធ្ងរ ហើយអ្នកធ្វើទារុណកម្មកាន់តែច្រើនឡើងយូរ ឬឆាប់ នឹងត្រូវនាំយកមកផ្តន្ទាទោស។

ចប់

*ដើម្បីស្វែងរកថារដ្ឋណាខ្លះដែលបាន ឬមិនទាន់បាន ផ្តល់សច្ចាប័នឲ្យសន្ធិសញ្ញាសិទ្ធិមនុស្សនានា រួមបញ្ចូលទាំងអនុសញ្ញាប្រឆាំងនឹងទារុណកម្ម សូមចូលទៅកាន់៖*
*http://treaties.un.org/Pages/Treaties.aspx?id=4&subid=A&lang=en*

*ចូលមើលវិបសាយរបស់មូលនិធិស្ម័គ្រចិត្ត អ.ស.ប. សម្រាប់ជនរងគ្រោះនៃអំពើទារុណកម្ម៖*
*http://www.ohchr.org/EN/Issues/Pages/TortureFundMain.aspx*

*សិក្សាអំពីអ្នករាយការណ៍ពិសេសស្តីពីទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ដោយឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប៖*
*http://www2.ohchr.org/english/issues/torture/rapporteur/*

*សម្រាប់ព័ត៌មានបន្ថែមអំពីឧត្តមស្នងការ អ.ស.ប. ទទួលបន្ទុកសិទ្ធិមនុស្ស៖*
*http://www.ohchr.org/EN/AboutUs/Pages/HighCommissioner.aspx*

*សម្រាប់ព័ត៌មានបន្ថែម ឬការស្នើសុំរបស់សារព័ត៌មាន សូមទាក់ទងអ្នកនាំពាក្យ លោក រូពើត កូលវិលឡេ (+41 22 917 9767 / rcolville@ohchr.org)  ឬមន្ត្រីខាងទំនាក់ទំនងសារព័ត៌មាន រ៉ាវីណា សែមដាសានី (+ 41 22 917 9310 / rshamdasani@ohchr.org) និង ហ្សាប៊ីអ៊ើ សេឡាយ៉ា (+ 41 22 917 9383 / xcelaya@ohchr.org).*

*ទំនាក់ទំនងជាមួយយើងតាមប្រព័ន្ធព័ត៌មានសង្គម៖*
*http://www.facebook.com/unitednationshumanrights*
*https://twitter.com/unrightswire*